World Food Programme
Programme Alimentaire Mondial
Programa Mundial de Alimentos
برنامج الأغذية العالمي

SAVING LIVES
CHANGING LIVES

# សេចក្តីប្រកាសព័ត៌មានរបស់កម្មវិធីស្បៀងអាហារពិភពលោក

៣០ សីហា ២០២១

## កម្មវិធីស្បៀងអាហារពិភពលោកសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីផ្តល់ស្បៀងជូនដល់ប្រជាពលរដ្ឋចំនួន៣០.០០០គ្រួសារ

រាជធានីភ្នំពេញ – ពេញមួយសប្តាហ៍នេះកម្មវិធីស្បៀងអាហារពិភពលោកសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីចែកស្បៀងជូនដល់ក្រុមគ្រួសារងាយរងគ្រោះចំនួន ៣០.០០០ គ្រួសារ ដែលក្នុងនោះមានប្រជាពលរដ្ឋសរុបដែលទទួលបានជំនួយនេះប្រហែល ១៥០.០០០នាក់ នៅក្នុងខេត្តចំនួនប្រាំគឺ សៀមរាប ឧត្តរមានជ័យ កំពង់ធំ កំពង់ឆ្នាំង និង ពោធិ៍សាត់។ ការចែកជំនួយនេះប្រព្រឹត្តទៅជារៀងរាល់ថ្ងៃចាប់ពីថ្ងៃទី ៣០ ខែសីហាដល់ថ្ងៃទី ៣ ខែកញ្ញា។ ជំនួយនេះផ្តល់ជូនដល់ក្រុមគ្រួសារដែលអាជ្ញាធរកំណត់ថាជាគ្រួសារងាយរងគ្រោះ មានអត្តសញ្ញាណប័ណ្ណគ្រួសារក្រីក្រ (IDPoor) និងមានកូនចុះឈ្មោះចូលរៀននៅតាមសាលាដែលមានការគាំទ្រពីកម្មវិធីផ្តល់ស្បៀងអាហារតាមសាលារៀន របស់កម្មវិធីស្បៀងអាហារពិភពលោក និងក្រសួងអប់រំ យុវជន និងកីឡា។

នេះគឺជាការចែកស្បៀងជុំទី៥ ហើយដែលកើតឡើងស្របពេលដែលរាជរដ្ឋាភិបាលកម្ពុជាបានបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះសម្ព័ន្ធភាពរដ្ឋអនុវត្តកម្មវិធីស្បៀងអាហារតាមសាលារៀន ដែលបើកដំណើរការ ជាផ្នែកមួយនៃកិច្ចប្រជុំកំពូលប្រព័ន្ធស្បៀងអាហារសកលនៅខែកញ្ញាឆ្នាំ ២០២១។ សម្ព័ន្ធនេះមានការចូលរួមពីរដ្ឋាភិបាល អង្គការសហប្រជាជាតិ សង្គមស៊ីវិល គ្រឹះស្ថានអប់រំ អង្គការមនុស្សធម៌ និងវិស័យឯកជនទាំងអស់ដែលទទួលស្គាល់ថា អាហារនៅតាមសាលាមានសារៈសំខាន់ណាស់ក្នុងការផ្លាស់ប្តូរប្រព័ន្ធអាហារនិងអាច ជួយឱ្យប្រទេសនិមួយៗអាចងើបពីវិបត្តសេដ្ឋកិច្ច-សង្គម ដែលបណ្តាលមកពីជំងឺកូវីដ -១៩ និងសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ប្រទេសកម្ពុជាគឺជាប្រទេសមួយក្នុងចំណោមប្រទេសចំនួន ៤០ ដំបូងគេបង្អស់ដែលបានចុះឈ្មោះចូលរួមក្នុងសម្ព័ន្ធភាពជាប្រវត្តិសាស្ត្រមួយនេះដែលអាចជួយការពារកុមារដែលងាយរងគ្រោះបំផុតពីភាពអត់ឃ្លាននិងកង្វះអាហារូបត្ថម្ភនានា។

លោកហង់ជួនណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡាបានមានប្រសាសន៍ថា ‟ អាហារសុខភាពដែលមានជីវជាតិនៅតាមសាលា អាចជួយបង្កើនការផ្តោតអារម្មណ៍របស់សិស្ស  និងធ្វើអោយ លទ្ធផលសិក្សារបស់គាត់កាន់តែល្អប្រសើរឡើង″ ។

WFP

"វាក៏ជួយសម្រាលបន្ទុកសេដ្ឋកិច្ចរបស់ក្រុមគ្រួសារសិស្សផងដែរ។ នេះហើយជាមូលហេតុដែលយើងចុះឈ្មោះចូលរួមជាមួយសម្ព័ន្ធភាពមួយនេះដើម្បីបង្ហាញពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលយើងក្នុងការធានាឱ្យបានថាគ្មានកុមារណាម្នាក់ត្រូវបានទុកចោលឡើយ" ។

អស់រយៈពេលម្ភៃឆ្នាំមកហើយ កម្មវិធីផ្តល់ស្បៀងអាហារតាមសាលារៀនរបស់កម្មវិធីស្បៀងអាហារពិភពលោកបានផ្តល់អាហារបំប៉នសំបូរជីវជាតិដល់កុមារនៅសាលាបឋមសិក្សានៅតំបន់ក្រីក្របំផុតមួយចំនួននៃប្រទេសកម្ពុជា។ មុនពេលមានជំងឺកូវីដ-១៩ កម្មវិធីនេះបានផ្តល់នូវអាហារសុខភាពនិងមានជីវជាតិដល់កុមារចំនួន ២២៣.000 នាក់នៅតាមសាលាគោលដៅចំនួន៩០៨ នៅក្នុងខេត្តចំនួន ៥ ។ ចាប់តាំងពីមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងការផ្អាកដំណើរការសាលារៀន សិស្សមិនបានទទួលទានអាហារពេលព្រឹកដែលមានជីវជាតិទៀតទេ។ បញ្ហានេះបានជះឥទ្ធិពលជាពិសេសដល់កុមារមកពីគ្រួសារក្រីក្របំផុតដែលភាគច្រើនរងការលំបាកដោយសារការបាត់បង់ចំណូលនិងការងារ។

លោកស្រី គ្លែរ  កូណាន់ តំណាងកម្មវិធីស្បៀងអាហារពិភពលោកប្រចាំនៅកម្ពុជា មានប្រសាសន៍ថា"កម្មវិធីស្បៀងអាហារពិភពលោកដឹងច្បាស់ថា អាហារូបត្ថម្ភល្អមានសារៈសំខាន់ណាស់សម្រាប់ការអភិវឌ្ឍរបស់កុមារ នេះហើយជាមូលហេតុដែលក្រុមការងាររបស់យើងខិតខំប្រឹងប្រែង ដើម្បី ឱ្យប្រាកដថាកញ្ចប់អាហារទាំងនេះទៅដល់ដៃក្រុមគ្រួសារងាយរងគ្រោះដើម្បីធានាថាកុមារនឹងមានអាហារទទួលទានក្នុងកំឡុងពេលវិបត្តិកូវីដមួយនេះ។

"គ្រួសារជាច្រើនបានរងផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរដោយសារជំងឺរាតត្បាតនេះ។ ជំនួយស្បៀងនេះត្រូវបានរៀបចំឡើងដើម្បីរួមចំណែកបំពេញបន្ថែមដល់ជំនួយគាំពារសង្គមផ្សេងៗទៀតរបស់រាជរដ្ឋាភិបាលកម្ពុជា ។ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះដៃគូទាំងអស់ដែលបានផ្តល់ការគាំទ្រ ជាពិសេស ក្រសួងអប់រំ យុវជន និងកីឡា និងក្រុមប្រឹក្សាជាតិគាំពារសង្គម។"

នេះគឺជាការចែកស្បៀងជុំទី៥ ក្នុងគោលបំណងកាត់បន្ថយផលប៉ះពាល់របស់ជំងឺកូវីដ-១៩ ទៅលើសេដ្ឋកិច្ចគ្រួសារងាយរងគ្រោះ។ ការចែកស្បៀងត្រូវបានធ្វើឡើងតាមរយៈបណ្តាញសាលារៀន ដោយមានការគាំទ្រពីមន្ទីរអប់រំ យុវជន និងកីឡា រដ្ឋបាលសាលារៀន អាជ្ញាធរភូមិឃុំ និងដៃគូអង្គការមិនមែនរដ្ឋាភិបាល។ របបស្បៀងមាន អង្ករ២៥គីឡូក្រាម ត្រីខកំប៉ុង និងប្រេងឆា។ ក្រៅពីនេះ កម្មវិធីស្បៀងអាហារពិភពលោកកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួងអប់រំ យុវជន និងកីឡា និងដៃគូដទៃទៀត ដើម្បីកែលម្អហេដ្ឋារចនាសម្ព័ន្ធសាលារៀននិងអគារសិក្សា ដែលជាវិធានការត្រៀមសម្រាប់ការចូលរៀនវិញប្រកបដោយសុវត្ថិភាព។

កម្មវិធីផ្តល់ស្បៀងអាហារតាមសាលារៀននៅកម្ពុជា និងជំនួយស្បៀងពិសេសនេះ អាចប្រព្រឹត្តទៅបានដោយមានជំនួយឧបត្ថម្ភពីរាជរដ្ឋាភិបាលកម្ពុជា រដ្ឋាភិបាលជប៉ុន ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) និងក្រសួងកសិកម្មនៃសហរដ្ឋអាមេរិក (USDA)។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង (អ៊ីម៉ែល chou.chea@wfp.org)៖
លោកស្រី ជា ជូ កម្មវិធីស្បៀងអាហារពិភពលោកកម្ពុជា ទូរស័ព្ទលេខ៖ +855 78 565 283